# County of Santa Clara

**Registrar of Voters**
1555 Berger Drive, Bldg. 2
San Jose, CA 95112
អាស័យដ្ឋានផ្ញើសំបុត្រ: P.O. Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) ទូរសារ: (408) 998-7314
www.sccvote.org


អ្នកបោះឆ្នោតជាទីគោរព,

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ខោនធី Santa Clara បានទទួលសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកសម្រាប់ ថ្ងៃទី 8 ខែមេសា ឆ្នាំ 2025 ទីក្រុង San José ការបោះឆ្នោតពិសេស ក្រុមប្រឹក្សា មណ្ឌលទី 3។

យើងកំពុងតែផ្ញើចេញនូវលិខិត **ស្រោមសំបុត្រនៃសេចក្ដីថ្លែងការណ៍កំណត់អត្តសញ្ញាណ** ដោយសារតែអ្នកមិនបានចុះ ហត្ថលេខា នៅលើស្រោមសំបុត្រសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកឬ ហត្ថលេខា មិនត្រូវគ្នានឹងកំណត់ត្រារបស់យើង។ ការបោះឆ្នោតរបស់អ្នកមិនអាចធ្វើដំណើរការបានទេលុះត្រាតែអ្នកធ្វើតាមជំហានដែលមានចែងក្នុងលិខិតនេះ។

ដើម្បីកែតម្រូវបញ្ហានេះ អ្នកត្រូវតែបំពេញនៅលើជម្រើសមួយ នៅក្នុងចំណោមជម្រើសដែលបានផ្ដល់អោយមានការណែនាំ នៅខាងក្រោយខ្នងនៃលិខិតនេះ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតត្រូវតែទទួលបានសេចក្ដីថ្លែងការណ៍នៅខាងក្រោយខ្នងនៃលិខិតនេះ ឬ អ្នកអាចមកកាន់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតដើម្បី ចុះហត្ថលេខា នៅលើស្រោមសំបុត្រ សន្លឹកឆ្នោតច្បាប់ដើមរបស់អ្នក មិនអោយយឺតជាង **18 ថ្ងៃក្រោយការបោះឆ្នោត ថ្ងៃសៅរ៍ ទី26 ខែមេសា ឆ្នាំ 2025**។ ដើម្បីធានាថាសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកត្រូវបានធ្វើដំណើរការ ហើយនិង ត្រូវបានរាប់បញ្ចូល។

<table>
<tr>
<td>County of Santa Clara<br>Registrar of Voters<br>1555 Berger Drive, Building 2<br>San Jose, CA 95112<br><br>លេខឥតគិតថ្លៃ៖ (866) 430-VOTE (8683)<br>ទូរសារ៖ (408) 998-7314<br>អ៊ីមែល៖ voterinfo@rov.sccgov.org</td>
<td>ម៉ោងធ្វើការធម្មតា៖<br>ថ្ងៃច័ន្ទ – ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក – ដល់ម៉ោង 5:00 ល្ងាច<br>(មិនរាប់បញ្ចូលនៅថ្ងៃបុណ្យឈប់សម្រាក)</td>
</tr>
<tr>
<td colspan="2">សម្រាប់ទិសដៅទៅកាន់ការិយាល័យរបស់យើង សូមចូលទៅកាន់:<br>https://vote.santaclaracounty.gov/news-notices/hours-locations-directions</td>
</tr>
</table>

***ស្រោមសំបុត្រនៃសេចក្ដីថ្លែងការណ៍កំណត់អត្តសញ្ញាណរបស់អ្នក***
***ត្រូវតែអោយបានទទួលដោយ ខោនធី Santa Clara ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត***
***មិនអោយយឺតជាង 18 ថ្ងៃបន្ទាប់ពីការបោះឆ្នោត ថ្ងៃសៅរ៍ ទី 26 ខែមេសា ឆ្នាំ 2025។***


Board of Supervisors: Sylvia Arenas, Betty Duong, Otto Lee, Susan Ellenberg, Margaret Abe-Koga
County Executive: James R. Williams

## សូមអានការណែនាំទាំងនេះដោយយកចិត្តទុកដាក់។

### ការបរាជ័យក្នុងការអនុវត្តទៅតាមការណែនាំទាំងនេះនឹងអាចបណ្តាលឲ្យសន្លឹកឆ្នោតរបស់អ្នកមិនត្រូវបានរាប់បញ្ចូល។

ដើម្បីឱ្យសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកត្រូវធ្វើដំណើរការបាន សូមបំពេញនៅលើសេចក្តីថ្លែងការណ៍ នៅខាងក្រោម ចុះហត្ថលេខា នៅលើបន្ទាត់ខាងលើ "ហត្ថលេខារបស់អ្នកបោះឆ្នោត" ហើយផ្ញើសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខារួចហើយត្រឡប់មកវិញ ដោយប្រើជម្រើសណាមួយក៏បាន៖

1. **ផ្ញើអ៊ីមែលសេចក្តីថ្លែងការណ៍ ដែលបានចុះហត្ថលេខា នឹង បានបំពេញរួចហើយ ទៅកាន់ការិយាល័យរបស់យើង**។ វាត្រូវតែទទួលដោយការិយាល័យរបស់យើងមិនអោយយឺតជាង **18 ថ្ងៃបន្ទាប់ពីការបោះឆ្នោត ថ្ងៃសៅរ៍ ទី 26 ខែមេសា ឆ្នាំ 2025**។ អាស័យដ្ឋាន អ៊ីមែល គឺ voterinfo@rov.sccgov.org។

2. **ផ្ញើសេចក្តីថ្លែងការណ៍ដែលបាន ចុះហត្ថលេខា និងបានបំពេញរួចហើយ មកកាន់ ការិយាល័យរបស់យើង នៅក្នុងស្រោមសំបុត្រដែលបានបិទតែមបង់ថ្លៃរួចហើយ**។ វាត្រូវតែអោយបានទទួលដោយការិយាល័យរបស់យើង មិនអោយយឺតជាង **18 ថ្ងៃក្រោយការបោះឆ្នោត ថ្ងៃសៅរ៍ ទី 26 ខែមេសា ឆ្នាំ 2025**។ មិនទទួលយកសំបុត្រដែលបានដាក់ត្រាស្លាកសញ្ញាប្រៃសណីយ៍ទេ។

3. **ទូរសារ សេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខា នឹង បានបំពេញរួចហើយ មកកាន់ការិយាល័យរបស់យើង**។ វាត្រូវតែអោយបានទទួលមិនអោយយឺតជាង **18 ថ្ងៃក្រោយការបោះឆ្នោត ថ្ងៃសៅរ៍ ទី 26 ខែមេសា ឆ្នាំ 2025**។ លេខទូរសារគឺ (408) 998-7314។

4. **មកកាន់ការិយាល័យចុះឈ្មោះ អ្នកបោះឆ្នោតដោយផ្ទាល់**។ អ្នកអាចមកកាន់ ការិយាល័យរបស់យើង នៅអាស័យដ្ឋាននៅខាងក្រោមនេះ ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច ដើម្បីចុះហត្ថលេខា នៅលើស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្ន ច្បាប់ដើមរបស់អ្នក ឬ ប្រគល់ សេចក្តីថ្លែងការណ៍ស្រោមសំបុត្រកំណត់អត្តសញ្ញាណ ត្រឡប់មកវិញ។ ត្រូវតែធ្វើ អោយបានមិនអោយយឺតជាង **18 ថ្ងៃបន្ទាប់ពីការបោះឆ្នោត ថ្ងៃសៅរ៍ ទី 26 ខែមេសា ឆ្នាំ 2025**។

*ចំណាំ៖ ហត្ថលេខាដែលបានផ្តល់ឱ្យអាចត្រូវបានដាក់ចូលទៅក្នុងកំណត់ត្រាអ្នកបោះឆ្នោតរបស់អ្នកសម្រាប់គោលបំណងប្រៀបធៀបហត្ថលេខានៅក្នុងការបោះឆ្នោតនាពេលខាងមុខ។*

## ស្រោមសំបុត្រនៃសេចក្តីថ្លែងការណ៍កំណត់អត្តសញ្ញាណ

ខ្ញុំ,________________________________________, គឺជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅ Santa Clara ខោនធី,
(ឈ្មោះអ្នកបោះឆ្នោត)

រដ្ឋ California។ ខ្ញុំសូមប្រកាសនៅក្រោមការពិន័យនៃការភូតកុហកដែលខ្ញុំបានស្នើសុំ(ឬ ខ្ញុំបានទទួល) ហើយបានប្រគល់សន្លឹកឆ្នោតបណ្តោះអាសន្នត្រឡប់មកវិញ ហើយថាខ្ញុំមិនមាន ហើយនឹងមិនបោះឆ្នោតលើសពីមួយសន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតនេះទេ។ ខ្ញុំជាអ្នករស់នៅក្នុងតំបន់ដែលខ្ញុំបានបោះឆ្នោត ហើយខ្ញុំពិតជាបុគ្គលដែលមានឈ្មោះនៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្ននេះប្រាកដមែន។ ខ្ញុំយល់ដឹងថា ប្រសិនបើខ្ញុំប្រព្រឹត្ត ឬ ប៉ុនប៉ងក្លែងបន្លំណាមួយ ដែលពាក់ព័ន្ធនឹងការបោះឆ្នោត ឬ ប្រសិនបើខ្ញុំជួយ ឬក្លែងបន្លំ ឬប៉ុនប៉ងជួយ ឬ ក្លែងបន្លំពាក់ព័ន្ធនឹងការបោះឆ្នោត ខ្ញុំអាចត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល 16 ខែ ឬ ពីរ ឬ បី ឆ្នាំ។ ខ្ញុំយល់ថាការខកខានក្នុងការចុះហត្ថលេខា ហើយនិងប្រគល់សេចក្តីថ្លែងការណ៍នេះ ត្រឡប់មកវិញត្រឹមថ្ងៃកំណត់មានន័យថាសន្លឹកឆ្នោតបណ្តោះអាសន្នរបស់ខ្ញុំនឹងមិនមានសុពលភាពទេ។

(បានចុះហត្ថលេខា)________________________________________

**ហត្ថលេខារបស់អ្នកបោះឆ្នោត** (មិនអាចទទួលយកលិខិតអំណាចរបស់មេធាវីបានទេ)

(សាក្សី)________________________________________

ប្រសិនបើអ្នកបោះឆ្នោតមិនអាចចុះហត្ថលេខាបាននោះអ្នកបោះឆ្នោតអាចបង្កើតធ្វើជាសញ្ញាសម្គាល់ដែលត្រូវមានសាក្សីម្នាក់។

ចុះកាលបរិច្ឆេទ ________________ នៃ ថ្ងៃ ________________________________, ឆ្នាំ 2025។

អាស័យដ្ឋានស្នាក់នៅ៖________________________________________

អាស័យដ្ឋានផ្លូវ ទីក្រុង លេខកូដតំបន់

អាស័យដ្ឋានផ្ញើសំបុត្រ៖________________________________________

អាស័យដ្ឋានផ្លូវ ទីក្រុង លេខកូដតំបន់

**County Santa Clara Registrar of Voters**
**អាស័យដ្ឋាន៖** 1555 Berger Drive, Building 2, San Jose, CA 95112
**អាស័យដ្ឋានផ្ញើសំបុត្រ៖** P.O. Box 611360, San Jose, CA 95161-1360
**លេខមិនគិតថ្លៃ៖** (866) 430-VOTE (8683); **ទូរសារ៖** (408)-998-7314; **គេហទំព័រ៖** www.sccvote.org

Board of Supervisors: Sylvia Arenas, Betty Duong, Otto Lee, Susan Ellenberg, Margaret Abe-Koga
County Executive: James R. Williams